# និយាយថាទេ ឮថាទេ

ព្រះវរបិតាសួគ៌ស្រឡាញ់ខ្ញុំ ហើយមានព្រះទ័យចង់ឲ្យខ្ញុំមានសុវត្ថិភាព ! ការនិយាយថា ទេ ពេលយើងត្រូវការនិយាយបែបនោះ និងការគោរព ដល់អ្នកដទៃទៀត ពេលពួកគេប្រាប់យើងថា ទេ ជារបៀបដែលយើងអាចរក្សាខ្លួនយើង និងអ្នកដទៃទៀតឲ្យមានសុវត្ថិភាព ។

ជួនកាលប្អូនៗត្រូវនិយាយថា ទេ ក្នុងរបៀបដ៏ល្អមួយ ។




ឥឡូវ ដល់វេនប្អូនៗហើយ ! សូមស្រមៃថាប្អូនៗត្រូវនិយាយថាទេ ក្នុងរបៀបដ៏ល្អមួយ ។ តើប្អូនអាចនិយាយថាដូចម្តេច ?

ជួនកាលប្អូនៗត្រូវនិយាយថា ទេ ក្នុងរបៀបដ៏រឹងប៉ឹងមួយ ។




ឥឡូវ ដល់វេនប្អូនៗហើយ ! សូមស្រមៃថាប្អូនៗត្រូវនិយាយថាទេ ក្នុងរបៀបដ៏រឹងប៉ឹងមួយ ។ តើប្អូនអាចនិយាយថាដូចម្តេច ?

ជួនកាលមនុស្សប្រាប់យើងថា ទេ ដើម្បីជួយយើងឲ្យមានសុវត្ថិភាព និងមានសុខភាពល្អ ។




ជួនកាលមនុស្សប្រាប់យើងថា ទេ ពេលពួកគេមិនស្រណុកចិត្ត ។




ឥឡូវ ដល់វេនប្អូនៗហើយ ! សូមស្រមៃថា មិត្តភក្តិម្នាក់ប្រាប់ប្អូនថា ទេ ហើយប្អូនមិនចូលចិត្តវាទេ ។ តើប្អូនគួរតែធ្វើយ៉ាងដូចម្តេច ?

ឥឡូវ ដល់វេនប្អូនៗហើយ ! សូមស្រមៃថា មនុស្សម្នាក់សុំប្អូនឲ្យឈប់ធ្វើអ្វីមួយ ។ តើប្អូនគួរតែធ្វើយ៉ាងដូចម្តេច ?

ចុះបើមនុស្សមិនស្តាប់ ពេលប្អូននិយាយថា ទេ នោះ ? ចុះបើពួកគេធ្វើបាបប្អូន ឬធ្វើអ្វីដែលអាក្រក់នោះ ?

- ★ ដើរចេញបើសិនប្អូនអាចធ្វើបាន ។
- ★ ប្រាប់មនុស្សពេញវ័យម្នាក់ដែលប្អូនទុកចិត្ត អំពីអ្វីដែលបានកើតឡើង ។
- ★ ចូរចាំថា វាមិនមែនជាកំហុសរបស់ប្អូននោះទេ ។
- ★ មិនថាមានអ្វីកើតឡើងទេ សូមដឹងថាព្រះវរបិតាសួគ៌របស់ប្អូន និងព្រះយេស៊ូវគ្រីស្ទតែងតែស្រឡាញ់ប្អូនជានិច្ច ។